- ចំពោះផ្ទាំងចំពោះតែកម្មសិក្សាការីវេជ្ជសាស្ត្រ ដែលបានបំពេញកម្មសិក្សាច្រើន បណ្ដុះបណ្ដាលវេជ្ជសាស្ត្រ ក្នុងវគ្គរយៈពេលពីមួយឆ្នាំឡើងទៅ ហើយជាវគ្គបណ្ដុះបណ្ដាលមានលក្ខណៈគ្រប់ប្រភេទ ។ មិនបានអនុញ្ញាតផ្ដល់ឲ្យ ឬពាក់ចំពោះវេជ្ជសាស្ត្រ ដែលមិនកំពុងរៀនសូត្រ និង សិក្សាវគ្គខ្លី ។

- កម្មសិក្សាការីវេជ្ជសាស្ត្រត្រូវស្លៀកពាក់ឯកសណ្ឋាននេះ តាមការកំណត់របស់សាលា និង ពាក់តែពេលចេញធ្វើការនៅមន្ទីរពេទ្យសាលា ។ ចំពោះកម្មសិក្សាការី ដែលបានរៀនសូត្រចប់វគ្គសិក្សាមិនអនុញ្ញាតឲ្យពាក់ឯកសណ្ឋាន និង ស្លាកសញ្ញានេះឡើយ ។

- **ការស្លៀកពាក់ :** ស្លៀកពាក់ឯកសណ្ឋាននេះ ត្រូវពាក់អមជាមួយ សញ្ញាទៅតាម តាមជំនាញសិក្សាកម្មសិក្សា ផ្លាកឈ្មោះ នៅលើហោប៉ៅស្ដាំ (ដូចផ្លាកឈ្មោះឯកសណ្ឋានការងារ) រូបរាងមាន បន្ទះក្រឡាហោប៉ៅស្ដាំសញ្ញាសំគាល់វគ្គសិក្សា ឬ អាវដែលនៅហោប៉ៅឆ្វេង នៅលើដៃអាវស្ដាំ មានពាក់ផ្លាកកងយោធពលខេមរភូមិន្ទ និង ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ស្បែកជើងពណ៌ខ្មៅ ។

មាត្រា ៣.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ និង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៤. អនុក្រឹត្យនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិង ត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៣ អនក្រ/បក**

**ស្ដីពីផលិតកម្ម អាហរណ-នីហរណកម្ម និង ពាណិជ្ជកម្ម**

**ឱសថបុរាណសំរាប់វិស័យសុខាភិបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការប្រព្រឹត្តិ ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៦/០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ ១៩៩៦ ស្តីពីការ គ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៧/អនក្រ.បក. ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង សុខាភិបាល ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំ ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨

**សំរេច**

**ជំពូកទី ១**

**បទបញ្ញត្តិទូទៅ**

**មាត្រា ១.** អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងផលិតកម្ម អាហរ័ណ-នីហរ័ណកម្ម និង ពាណិជ្ជកម្មឱសថ បុរាណ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.** ឱសថបូរាណគឺជាគការជាតិសំរាប់ប្រើប្រាស់ក្នុងការបង្ការ ឬ ព្យាបាលជម្ងឺ មនុស្ស សត្វ មាន ៖

- រុក្ខជាតិ ឬ សត្វ សិលាជាតិ ដែលមិនទាន់កែច្នៃ ឬ បានកែច្នៃតាមវិធីសាស្ត្រសាមញ្ញ
- ផលិតផលដែលផ្សំ ឬ ផលិតឡើងដោយសារជាតិមួយមុខ ឬ ច្រើនមុខ ដែលមាន រចនាសម្ព័ន្ធគីមីមិនទាន់ច្បាស់លាស់ និង មានប្រភពពីរុក្ខជាតិ សត្វ ឬ សិលាជាតិ ។

**មាត្រា ៣.** ផលិតកម្ម អាហរ័ណ-នីហរ័ណកម្ម និង ពាណិជ្ជកម្មឱសថបូរាណ អាចប្រព្រឹត្តិទៅបាន លុះត្រាតែ មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

## ជំពូក ២
## សិទ្ធិធ្វើអាជីវកម្មឱសថបុរាណ

មាត្រា ៤._ ឱសថការីដែលអាចមានសិទ្ធិធ្វើផលិតកម្ម អាហរ័ណ-នីហរ័ណកម្ម ឱសថបុរាណបានត្រូវ មាន លក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រឱសថការី ទទួលស្គាល់ដោយក្រសួងសុខាភិបាល
- មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់ អាចបំពេញការងារបាន ។

មាត្រា ៥._ គ្រូថ្នាំបុរាណដែលមានសិទ្ធិធ្វើពាណិជ្ជកម្មឱសថបុរាណ បានត្រូវមានលក្ខណៈសម្បត្តិ ដូចខាង ក្រោម៖

- មានសញ្ជាតិខ្មែរ
- មានការយល់ដឹងក្នុងការផ្សំឱសថបុរាណពីរុក្ខជាតិ សត្វ ឬ សិលាជាតិ និង ការ ពិនិត្យព្យាបាលជម្ងឺតាមញ្ញាតាមវេជ្ជសាស្ត្របុរាណ ដែលមានវិញ្ញាបនបត្រ គ្រូថ្នាំ បុរាណ ទទួលស្គាល់ដោយក្រសួងសុខាភិបាល
- មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់ អាចបំពេញការងារបាន ។

មាត្រា ៦._ ក្រសួងសុខាភិបាលអាចអនុញ្ញាតឲ្យឱសថការី និងគ្រូថ្នាំបុរាណបរទេសប្រកបវិជ្ជាជីវៈ ឱសថបុរាណ ក្នុងព្រះរាជាណាចក្រកម្ពុជាបាន ក្នុងករណីយល់ឃើញថា មានតម្រូវការចាំបាច់ក្នុងសង្គម ជាតិ ។

មាត្រា ៧._ ឱសថបុរាណដែលអាចផលិត អាហរ័ណ-នីហរ័ណបាន ត្រូវមានទិដ្ឋការ ឬបញ្ជីកាយល់ព្រមពីក្រសួង សុខាភិបាល ។

មាត្រា ៨._ ក្រសួងសុខាភិបាលកំណត់ដោយប្រកាសនូវ ៖

- បែបបទ និងលក្ខខ័ណ្ឌ ក្នុងការសុំបើក ឬប្តូរទីតាំង-ឬផ្ទេរម្ចាស់និធិនៃគ្រឹះស្ថានផលិត គ្រឹះស្ថានអាហរ័ណ-នីហរ័ណ និងអាគារលក់ឱសថបុរាណ ។
- បែបបទ និង លក្ខខ័ណ្ឌក្នុងការសុំទិដ្ឋការ ឬបញ្ជីកាឱសថបុរាណ
- បែបបទ និង លក្ខខ័ណ្ឌបច្ចេកទេសគ្រប់គ្រង និង ថែរក្សាឱសថបុរាណ
- បែបបទ និង លក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថបុរាណ
- បែបបទ ផលិតកម្ម អាហរ័ណ-នីហរ័ណកម្ម និង ពាណិជ្ជកម្មឱសថបុរាណ

**មាត្រា ៩.**_ ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលចំពោះ ៖

- ការបើក ការប្តូរទីតាំង និង ការប្តូរអ្នកទទួលខុសត្រូវនៃគ្រឹះស្ថានផលិត គ្រឹះស្ថានអាហរ័ណ-នីហរ័ណ និង អគារលក់ឱសថបុរាណ
- ការផលិតអាហរ័ណ-នីហរ័ណ ស្តុកឱសថបុរាណ និង វត្ថុធាតុដើមសំរាប់ឱសថបុរាណ
- ការផ្សព្វផ្សាយឱសថបុរាណ ។

## ជំពូកទី ៣

## ផលិតកម្មឱសថបុរាណ

**មាត្រា ១០.**_ ផលិតកម្មឱសថបុរាណជាទ្រង់ទ្រាយឧស្សាហកម្ម ត្រូវប្រព្រឹត្តក្នុងគ្រឹះស្ថានផលិតឱសថដែលមានការរៀបចំសមស្របតាមលក្ខខ័ណ្ឌបច្ចេកទេសកំណត់ដោយប្រកាសក្រសួងសុខាភិបាល ។

**មាត្រា ១១.**_ ផលិតកម្មឱសថបុរាណ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និង ការទទួលខុសត្រូវរបស់ឱសថការីមួយរូប ឬ ច្រើនរូបទៅតាមទំហំផលិត

## ជំពូកទី ៤

## អាហរ័ណ-នីហរ័ណកម្មឱសថបុរាណ

**មាត្រា ១២.**_ អាហរ័ណ-នីហរ័ណកម្មឱសថបុរាណ ត្រូវធ្វើឡើងតាមរយៈស្ថាបនអាហរ័ណ-នីហរ័ណ ឱសថ ដែលមានរៀបចំសមស្របតាមលក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល ។

**មាត្រា ១៣.**_ ឱសថបុរាណដែលសុំនាំចូល ត្រូវជ្រើសរើសក្នុងបញ្ជីឱសថបុរាណ ដែលបានចុះបញ្ជិកា រួចហើយនៅក្រសួងសុខាភិបាល ។

ឱសថបុរាណដែលបាននាំចូលហើយ ត្រូវមានទំរង់បង្ហាញ និង មានគុណភាពល្អត្រឹមត្រូវតាមឱសថគំរូដែលបានតំកល់ ។

## ជំពូកទី ៥

## ពាណិជ្ជកម្មឱសថបុរាណ

**មាត្រា ១៤.**_ ការតាំងលក់ ការលក់ និង ការស្តុកឱសថបុរាណត្រូវប្រព្រឹត្តទៅនៅក្នុងអគារលក់ឱសថ បុរាណ ដែលមានការរៀបចំសមស្របតាមលក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល។

**មាត្រា ១៥.**_ អាគារលក់ឱសថបុរាណត្រូវមានវត្តមានរបស់គ្រូបុរាណ ដើម្បីគ្រប់គ្រងសកម្មភាពក្នុងអគារ របស់ខ្លួន ។

*ករណីអវត្តមានគ្រូថ្នាំបុរាណទទួលខុសត្រូវ ត្រូវមានគ្រូបុរាណមួយរូបទៀតជំនួស ដោយមានការ* អនុញ្ញាតពីក្រសួងសុខាភិបាល ។

**មាត្រា ១៦.**_ ត្រូវហាមឃាត់ ៖

១- ការលក់ឱសថបូរាណក្លែងក្លាយ គ្មានគុណភាព

២- ការលក់ឱសថបូរាណ ដែលផ្សំលាយជាមួយឱសថសម័យ

៣- ការលក់ឱសថបូរាណគ្រោះថ្នាក់ ដែលមានក្នុងបញ្ជីហាមឃាត់របស់ក្រសួង សុខាភិបាល

៤- ការប្រកបអាជីវកម្មផ្សេងទៀតក្នុងអគារលក់ឱសថបូរាណ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.**_ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.**_ សារេរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង ក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

បានចុះហត្ថលេខា និង ត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២៤ អនក្រ/បក

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងកិច្ចការនារី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា